**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
នាយកដ្ឋានអង្គការសហប្រជាជាតិ

សេចក្តីប្រកាសព័ត៌មាន

## «ព្រះរាជាណាចក្រកម្ពុជា បានជាប់ឆ្នោតសាជាថ្មី ជាសមាជិកនៃក្រុមប្រឹក្សាសម្របសម្រួលកម្មវិធីរបស់អង្គការយូអិនអេដស៍ សម្រាប់អាណត្តិ ២០២៦-២០២៨»

ព្រះរាជាណាចក្រកម្ពុជាមានកិត្តិយសជម្រាបអំពីការជាប់ឆ្នោតជាថ្មីម្តងទៀតជាសមាជិកក្រុមប្រឹក្សាសម្របសម្រួលកម្មវិធីរបស់អង្គការយូអិនអេដស៍ សម្រាប់តំបន់អាស៊ី-ប៉ាស៊ីហ្វិក អាណត្តិ ២០២៦-២០២៨ ដែលនឹងចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៦។ សេចក្តីសម្រេចនេះ ត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំពេញអង្គលើកទី២២ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម (ECOSOC) របស់អង្គការសហប្រជាជាតិ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៥ នាទីក្រុងញូវយ៉ក ដែលនេះជាសមិទ្ធផលដ៏សំខាន់មួយ បញ្ជាក់អំពីការប្តេជ្ញាចិត្តដ៏ខ្ជាប់ខ្ជួនរបស់កម្ពុជា ក្នុងកិច្ចខិតខំប្រឹងប្រែងសកលចំពោះការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ និងការលើកកម្ពស់គំនិតផ្តួចផ្តើមសុខភាពសាធារណៈ។

ក្រុមប្រឹក្សាសម្របសម្រួលកម្មវិធីរបស់អង្គការយូអិនអេដស៍ គឺជាអង្គភាពដឹកនាំ ដែលមានភារកិច្ចកំណត់ទិសដៅយុទ្ធសាស្ត្រ និងធានាឱ្យបាននូវប្រសិទ្ធភាពក្នុងការចាត់វិធានការសកល ឆ្លើយតបនឹងជំងឺអេដស៍។ ការជាប់ជាសមាជិកសាជាថ្មីនៃក្រុមប្រឹក្សាសម្របសម្រួលកម្មវិធីដ៏សំខាន់នេះ ឆ្លុះបញ្ចាំងអំពីទំនុកចិត្ត និងការទទួលស្គាល់ពីសំណាក់សហគមន៍អន្តរជាតិ ចំពោះការចូលរួមចំណែក និងភាពជាអ្នកដឹកនាំរបស់កម្ពុជា ក្នុងការពង្រឹងអាទិភាពសុខភាពសកល។ ក្នុងឱកាសដែលកម្ពុជានឹងបន្តអនុវត្តនូវភារកិច្ចដ៏សំខាន់នេះ កម្ពុជានឹងបន្តដើរតួនាទីក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ តាមរយៈការអនុវត្តយុទ្ធសាស្ត្រ គោលនយោបាយបុរេសកម្ម ការចាត់វិធានការគោលដៅ និងភាពជាដៃគូជាមួយភាគីពាក់ព័ន្ធតំបន់ និងអន្តរជាតិ។

រាជរដ្ឋាភិបាលកម្ពុជាសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះរដ្ឋសមាជិកទាំងអស់ដែលបានគាំទ្រ និងមានទំនុកចិត្តមកលើកម្ពុជា។ កម្ពុជានឹងបន្តចូលរួមយ៉ាងសកម្មក្នុងក្រុមប្រឹក្សាសម្របសម្រួលកម្មវិធីរបស់អង្គការយូអិនអេដស៍ ដើម្បីពង្រឹងគំនិតផ្តួចផ្តើមសុខភាពសាធារណៈដែលប្រកបដោយសុវត្ថិភាព បរិយាបន្ន និងភាពធន់ ក្នុងសាមគ្គីភាព និងទំនួលខុសត្រូវរួម៕

ថ្ងៃអង្គារ ៧រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
ភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៥

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh